# សឺន សាន
## (១៩១១ - ២០០០)

*លោក សឺន សាន ជាវរជនខ្មែរ បានឆ្លងកាត់ស្គាល់នយោបាយស្រុកខ្មែរយ៉ាងច្បាស់ នៅចុងសតវត្សទី ២០ នេះ ។ នៅទសវត្ស ៨០ គាត់បានបង្កើត "រណសិរ្សជាតិ រំដោះប្រជាពលរដ្ឋខ្មែរ" (រ.ជ.រ.ប.ខ.) ប្រឆាំងទៅរបប ហេង សំរិន ឧបត្ថម្ភដោយសារ វៀតណាម និង ប្រឆាំងទៅ កម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហម ប៉ុល ពត ដែលទីបំផុត លោកបានក្លាយជា នាយករដ្ឋមន្ត្រី រដ្ឋាភិបាលត្រីភាគី មាន ៖ សីហនុ និយម, សឺន សាន, កម្ពុជាប្រជាធិបតេយ្យ ។ រដ្ឋាភិបាលត្រីភាគី បានចូលរួមចរចាឲ្យមានកិច្ចព្រមព្រៀងសន្តិភាព ក្រុងប៉ារីស ឆ្នាំ ១៩៩១ ។ ថ្វីត្បិតតែគាត់អនិច្ចកម្មទៅហើយក្តី ឧត្តមគតិស្នេហាជាតិមាតុភូមិ បានត្រូវខ្មែរជំនាន់ក្រោយរក្សាបន្ត មិនឲ្យបាត់បង់ឡើយ ។*

### ជីវប្រវត្តិ

*លោក សឺន សាន កើតនៅថ្ងៃទី ៥ តុលា ១៩១១ នៅទីក្រុងភ្នំពេញ ។ ឪពុក ឈ្មោះ សឺន សាច់ ម្តាយ ឈ្មោះ នាង សន ។ លោក សឺន សាច់ ជាអ្នកបន្តវង្សត្រកូល អ្នកឧកញ៉ា សេនាបតី សឺង គុយ វីរបុរសជាតិ កម្ពុជាក្រោម អតីត អភិបាលស្រុក ខេត្តព្រះត្រពាំង ដែលបានពលីកម្មប្តូរជីវិត ព្រមឲ្យយួនកាត់ក្បាល ជាថ្នូរនឹងការថែរក្សាជំនឿលើ ព្រះពុទ្ធសាសនា និកាយថេរវាទ សម្រាប់ខ្មែរក្រោមទាំងមូល ។*

*នៅឆ្នាំ ១៩១៧ លោក សឺន សាន បានចូលរៀន សាលាបឋមសិក្សា មីស្ស ក្រុងភ្នំពេញ ។ នៅឆ្នាំ ១៩២៧ លោកបានបន្តការសិក្សានៅស្រុកបារាំង បានទទួលសញ្ញាប័ត្រជាន់ខ្ពស់ ខាងពាណិជ្ជកម្ម (**HEC**) ក្រុងប៉ារីស នៅឆ្នាំ ១៩៣៣ ។ ពេលត្រឡប់ចូលកម្ពុជាវិញ នៅឆ្នាំ ១៩៣៥ គាត់បានបំរើរដ្ឋការអាណានិគមបារាំង ក្នុងឋានៈជា ភូឈ្មួយ ខេត្តសៀមរាប, ឆ្នាំ ១៩៣៧ ជា ភូឈ្មួយ ខេត្តបាត់ដំបង ។ នៅឆ្នាំ ១៩៣៩ គាត់បានចាកចេញពីរដ្ឋការ មកកិច្ចការជំនួញ ។ នៅឆ្នាំ ១៩៤០ គាត់ជា សមាជិក នៃ បេសកកម្មសេដ្ឋកិច្ចខ្មែរ នៅតូក្យូ ដើម្បីចរចាការនាំចេញអង្ករខ្មែរ ។*

### ក្នុង រដ្ឋាភិបាល

*បន្ទាប់ពី សង្គ្រាមលោកលើកទី ២ លោក សឺន សាន បានវិលមកការងារសាធារណៈវិញ ។ តាំងពី ឆ្នាំ ១៩៤៧ គាត់ជា រដ្ឋមន្ត្រី ហិរញ្ញវត្ថុ (១៥/១២/១៩៤៦-២០/៧/១៩៤៧) របស់រដ្ឋាភិបាល ស៊ីសុវត្ថិ យុត្តិវង្ស, ឧបនាយករដ្ឋមន្ត្រី (២៥/៧/១៩៤៧-២៤/៨/១៩៤៨)*



*និង ពីឆ្នាំ ១៩៥០ ជា រដ្ឋមន្ត្រី ការបរទេស ។ នៅឆ្នាំ ១៩៥៥ ដោយមានសហការពី ប្រវត្តិវិទូ និង សេដ្ឋកិច្ចវិទូ បារាំង **ACHILLE DAUPHIN-MEUNIER** លោកបានបង្កើត "**ធនាគារជាតិខ្មែរ**" ដែលគាត់ក្លាយជា ទេសាភិបាល នៃ ធនាគារនេះ តាំងពីឆ្នាំនោះមក រហូតដល់ឆ្នាំ ១៩៦៨ ព្រមពេលជាមួយគ្នា គាត់កាន់តំណែងត្រួតត្រាជា រដ្ឋមន្ត្រី ផង ។ ជាសរុប ជាងម្ភៃឆ្នាំ លោក សឺន សាន មានឋានៈ ជា រដ្ឋមន្ត្រី យ៉ាងតិច ១៧ លើក និង ជា រដ្ឋមន្ត្រីទី ១ មួយលើក (០១/០៥/១៩៦៧-៣១/០១/១៩៦៨) ។ នៅឆ្នាំ ១៩៦៩ លោក សឺន សាន បានទទួលងារជា "សម្តេច បវរសេដ្ឋាធិបតី" ពី សម្តេច សីហនុ ។*

### ចូលរួម ការចរចា - សន្និសីទ

*លោក សឺន សាន, លោក ប៉ែន នុត, លោក សម សារី ..., បានចូលរួមទាមទារឯករាជ្យ ពីបារាំង នៅឆ្នាំ ១៩៥០ ។ លោកបានចូលរួមសន្និសីទជាច្រើន ដូចជា សន្និសីទសង់ហ្វ្រង់ស៊ីស្កូ ឆ្នាំ ១៩៤៨, សន្និសីទ វ៉ាស៊ិនតោន, សន្និសីទ ហ្សឺណែវ ឆ្នាំ ១៩៥៤, ការរៀបចំសេចក្តីសំរេច នាឆ្នាំ ១៩៦២ របស់តុលាការអន្តរជាតិ ក្រុងឡាអេ ស្តីពី ប្រាសាទព្រះវិហារ ។*

### សម័យ សាធារណរដ្ឋខ្មែរ

*ទោះបីជាគាត់មិនយល់ស្របទាំងស្រុង គំនិតនយោបាយរបស់ សម្តេច សីហនុ លោក សឺន សាន ក៏មិនយល់ស្របតាម លោក លន់ នល់ ឲ្យមានការទំលាក់ សម្តេច សីហនុ ពីប្រមុខរដ្ឋ ដែរ នាថ្ងៃ ១៨ មីនា ១៩៧០ ។ គាត់បានដកខ្លួនមករស់នៅប៉ារីស ។ នៅ ខែមិថុនា ១៩៧០ គាត់បានទៅប៉េកាំង ជួប សម្តេច សីហនុ ដើម្បីសំរុះសំរួល ។ រហូតមកដល់ ឆ្នាំ ១៩៧១ នយោបាយមេអណ្តើករបស់គាត់ បានទទួលការគាំទ្រពី អ្នកការទូត, អ្នកនយោបាយ ខ្មែរ-បារាំង-ចិន ជាច្រើន ។ ប៉ុន្តែ នៅឆ្នាំ ១៩៧២ ជូ អេនឡាយ រដ្ឋមន្ត្រីទី ១ ចិន បានច្រានចោលគំនិតគាត់ ហើយ លោក លន់ នល់ ក៏បានក្លាយជា "ប្រធានាធិបតី" នៃ របបសាធារណរដ្ឋ ។*

### សម័យ កម្ពុជាប្រជាធិបតេយ្យ

*នៅពេលខ្មែរក្រហមយកអំណាចបាន គាត់នៅស្រុកបារាំង ។ នៅឆ្នាំ ១៩៧៦ គាត់បានបង្កើត "**សមាគមទូទៅ ខ្មែរនៅបរទេស**" (**AGKE**) ដែលតាមរយៈសមាគមនេះ គាត់បានទទួលជំនួយ សម្ភារៈយោធា, ហិរញ្ញវត្ថុ ពីអាមេរិក ដើម្បីទ្រទ្រង់ក្រុមអតីត ទាហាន, នាយទាហាន សាធារណរដ្ឋខ្មែរ ប្រឆាំងទៅខ្មែរក្រហម ។*

### ***ក្រុមអ្នកតស៊ូ នៅក្នុង រ.ជ.រ.ប.ខ.***

*នៅខែតុលា ១៩៧៩ របបខ្មែរក្រហមបានធ្លាក់ និង ជំនួសដោយ "សាធារណរដ្ឋប្រជាមានិត" ហេង សំរិន បង្កើត និង គាំទ្រដោយសារយួន លោក សឺន សាន បានបង្កើត **"រណសិរ្សជាតិ រំដោះប្រជាពលរដ្ឋខ្មែរ" (រ.ជ.រ.ប.ខ.)** ប្រឆាំងទៅរបប ហេង សំរិន និង មិនធានាឲ្យខ្មែរក្រហមវិលត្រឡប់មកវិញឡើយ ។ ប៉ុន្តែ ផ្លូវទី ៣ នេះ មិនអាចធ្វើបានឡើយ ។ តាំងពីឆ្នាំ ១៩៨២ គាត់ក៏បានចូលទៅក្នុង រដ្ឋាភិបាលត្រីភាគី បង្កើតឡើងដោយ សម្តេច សីហនុ ។ គាត់ជា រដ្ឋមន្ត្រីទី ១ នៃ រដ្ឋាភិបាល ៣ ភាគី ៖ សីហនុ និយម, សឺន សាន (អតីត ទាហានសាធារណរដ្ឋ), ខ្មែរក្រហម ។ ដោយហេតុថា ចំនួនកងកម្លាំង រ.ជ.រ.ប.ខ. មានចំនួនតិច និង ដោយមិនហ៊ានបរិហារ ការរំលោភសម្លាប់របស់ខ្មែរក្រហម មកលើ រ.ជ.រ.ប.ខ. ដើម្បីបានបន្តជំនួយពីចិន ឥរិយាបថនេះ បានបង្កើតឲ្យមានការប្រេះឆា ទាស់ប្រឆាំងគ្នា ក្នុងជួរ រ.ជ.រ.ប.ខ. ប៉ុន្តែ គាត់បានរក្សាជាប់ការចាត់ការនយោបាយ ។ កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ឆ្នាំ ១៩៩១ ខែតុលា ជាស្នាដៃ ជាការតស៊ូនយោបាយដោយវីរភាពរបស់គាត់ ។*

### ***ការវិលចូល ភ្នំពេញ***

*គាត់បានវិលចូលភ្នំពេញ នៅខែធ្នូ ១៩៩១ និង បានធ្វើការផ្លាស់ប្តូរ រ.ជ.រ.ប.ខ. ជា **"គណបក្ស ប្រជាធិបតេយ្យសេរី និយមព្រះពុទ្ធសាសនា"** (**PLDB**) ដើម្បីចូលរួមបោះឆ្នោតសភាធម្មនុញ្ញ នៅខែឧសភា ១៩៩៣ រៀបចំដោយ អ.ស.ប. អ៊ុនតាក់ (**UNTAC**) ។ គណបក្ស នេះ បានទទួល ១០ អាសនៈ ក្នុងចំនួន ១២០ អាសនៈ ។ គាត់ជាប់ជា ប្រធាន និង មើលការតាក់តែងរដ្ឋធម្មនុញ្ញថ្មី ដែលបានប្រកាសឲ្យប្រើ នៅខែកញ្ញា ១៩៩៣ ។ បន្ទាប់ពីបានបង្កើតរបប **"រាជាធិបតេយ្យ អាស្រ័យរដ្ឋធម្មនុញ្ញ"** ឡើងវិញ គាត់បានដកខ្លួនថយពីនយោបាយ និង ប្រគល់តំណែង ប្រធានសភា ទៅ លោក ជា ស៊ីម ។ នៅខែកក្កដា ១៩៩៥ គាត់បានប្រគល់ នាយកគណបក្ស ទៅ លោក អៀង មូលី ជា រដ្ឋមន្ត្រី ក្រសួងពត៌មាន ។ ក្នុងជីវិតនយោបាយរបស់គាត់ មានជាប់ស្នាមដោយបរាជ័យ បរាជ័យដោយពុំបានឃើញមានរបបពហុបក្សតាមលក្ខណៈប្រជាធិបតេយ្យសេរីនិយម នៅស្រុកខ្មែរ ។*

*គាត់បានដកខ្លួនមកនៅប៉ារីស ដែលនៅទីនោះ គាត់បានទទួលអនិច្ចកម្ម នៅថ្ងៃទី ១៩ ធ្នូ ឆ្នាំ ២០០០ ក្នុងអាយុ ៨៩ ឆ្នាំ ។ សពរបស់គាត់ បានយកទៅបូជានៅភ្នំពេញ ចំពោះវត្តមាន មហាក្សត្រ សីហនុ និង មុនីនាថ ។*

*សូមអានបន្ថែម កាលប្រវត្តិវិជ្ជា ឆ្នាំ ១៨៣៥-២០១២ ។*











*លោក**ឌៀនដែល**កើតឆ្នាំ១៩៣២ នៅខេត្តឃ្លាំងកម្ពុជាក្រោម។ ពីឆ្នាំ ១៩៧០-១៩៧៥ លោកបានបំរើជាតិក្នុងកងទ័ពសាធារណរដ្ឋខ្មែរ បានទទួលឧត្តមសេនិយទោមេបញ្ជាការកងពលធំលេខ២ឆ្នាំ១៩៧២ - អភិបាលខេត្តកណ្តាលពីឆ្នាំ១៩៧៤រហូតដល់ថ្ងៃទី១៦ មេសា១៩៧៥។ លោកបានទទួលមរណភាពនៅថ្ងៃទី១៣ខែកុម្ភៈ២០១៣ នៅភ្នំពេញ។ល*




**លោកឧត្តមសេនិយទោ ឌៀន ដែល អ្នកបង្កើត"រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ" នៅថ្ងៃទី៥មិនា១៩៧៩ជាមួយលោក សឺន សាន**

## SON SANN (1911-2000)

avec wikipedia

**Son Sann** (1911-2000) est un ancien Premier ministre cambodgien
Il fut aussi le chef du FLNPK (Front de libération nationale du peuple khmer) puis du Parti libéral démocratique et bouddhiste qui était, dans les années 1980, la troisième composante de l'opposition au gouvernement de Phnom Penh à côté des troupes khmères rouges et de celles fidèles à Norodom Sihanouk.
C'est à ce titre qu'il participa aux négociations qui aboutirent aux accords de Paris de 1991.

**Biographie**
Il est né le 5 octobre 1911 à Phnom Penh, dans une famille khmère Krom (minorité khmère du Sud-Vietnam)
Son Sann part étudier en France et, après un passage par le collège Saint-Aspais de Melun puis le Lycée Louis-le-Grand, sort diplômé de HEC Paris en 1933.
À son retour au Cambodge, en 1935, il sert l'administration française en tant que vice-gouverneur de Siem Reap puis, en 1937, de Battambang.
En juin 1939, il quitte l'administration pour s'essayer au monde des affaires.
En décembre 1940, il est membre d'une mission économique cambodgienne envoyée à Tokyo pour négocier l'exportation de riz au Japon.
À partir de 1941, il est chargé de former le nouveau roi, Norodom Sihanouk dans le domaine de l'économie.

**Au gouvernement**
Une fois la paix revenue, il retrouve la fonction publique et, dès 1947, il devient ministre des finances, vice-président du conseil puis, à partir de 1950, ministre des affaires étrangères. En 1954 c'est en tant que ministre des affaires étrangères qu'il part représenter le Royaume du Cambodge à la conférence qui aboutit aux accords de Genève, marquant la fin de la première guerre d'Indochine.
De retour, il crée, avec l'aide d'Achille Dauphin-Meunier (auquel l'avait présenté Edmond Vivier), la **Banque Nationale du Cambodge** dont il devient le premier Gouverneur en 1955, gardant ce poste jusqu'en 1968 et le cumulant avec ses fonctions ministérielles.
En tout, en une vingtaine d'années, il occupera pas moins de dix sept postes différents dans des ministères, dont celui de Premier ministre de 1967 à 1969.

**Période de la République khmère**
Même s'il n'a jamais vraiment partagé les idées politiques du prince Norodom Sihanouk, lorsque ce dernier est déposé le18 mars 1970, il décide de quitter le pays pour Paris.



En juin 1970, il va à Pékin pour tenter de réconcilier Norodom Sihanouk et Lon Nol qui l'avait déposé. Il poursuivit ses efforts, même après la proclamation en octobre de la République khmère. À la fin de 1971, il avait gagné le soutien de plusieurs diplomates et politiciens cambodgiens, français et chinois. Toutefois, en 1972, le Premier ministre Zhou Enlai rejette l'initiative et Lon Nol y répond en s'autoproclamant Président de la République.

**Période du Kampuchéa Démocratique**
Il était revenu en France quand le 17 avril 1975, les khmers rouges s'emparèrent du pouvoir à Phnom Penh.
En 1976, il crée et préside l'Association générale des Khmers à l'étranger **(AGKE)** par laquelle avec l'aide matérielle et financière des Américains, il finance les groupes d'anciens soldats et officiers républicains combattant le régime de Pol Pot.

**Résistance dans le FLNKP**
En octobre 1979, alors que les khmers rouges avaient dû céder le pouvoir à la République Populaire du Kampuchéa mise en place par les Vietnamiens, Son Sann fonda le Front de libération nationale du peuple khmer **(FLNPK)** d'inspiration républicaine, pour s'opposer au régime de Phnom Penh sans pour autant cautionner un retour des khmers rouges.
Malheureusement cette troisième voie s'avéra peu viable et, dès 1982, il intègre, en tant que premier ministre, un nouveau gouvernement de coalition en exil créé par Norodom Sihanouk et comprenant les khmers rouges.
Toutefois, la faiblesse militaire du FLNPK et le fait de devoir passer sous silence les exactions perpétrées contre ses propres troupes par les Khmers rouges afin de continuer à toucher les fonds du gouvernement chinois conduit à des dissensions dans les rangs du parti; mais Son Sann réussit néanmoins à en conserver la direction politique.

Son attitude critique envers le pouvoir en place à Phnom Penh lui valut de prendre part aux négociations qui aboutirent à la conférence de paix sur le Cambodge et à la signature des accords de Paris en octobre 1991.

**Retour à Phnom Penh**
Il retourne à Phnom Penh en décembre 1991 et transforme le FLNPK en Parti libéral démocratique et bouddhiste **(PLDB)** afin de préparer les élections de mai 1993 qui se tiennent sous l'égide de l'Autorité Provisoire des Nations Unies au Cambodge **(APRONUC)**.

Le parti ne gagne que 10 des 120 sièges de la nouvelle assemblée constituante. Son Sann en est élu président et supervise donc la rédaction de la nouvelle constitution qui fut promulguée en septembre.
Après le rétablissement de la monarchie constitutionnelle, Son Sann décide de se retirer de la vie publique et cède son siège de président de l'Assemblée nationale à Chea Sim.
Norodom Sihanouk pense alors à lui et le nomme conseiller personnel.
En juillet 1995, il doit laisser la présidence de son parti à Ieng Mouly, alors ministre de l'Information.

La fin de sa vie est marquée par une série d'échecs, entre l'impossibilité d'établir une démocratie pluraliste et l'affaiblissement de son parti qui ne survivra pas aux luttes intestines.
C'est sur cette déconvenue qu'il se retira à Paris où **il décède** d'une crise cardiaque, **le 19 décembre 2000**. Son corps est ramené à Phnom Penh et est incinéré en présence de LL. MM. le Roi Norodom Sihanouk et la Reine Monique. **Ses cendres reposent dans un stûpa à Sri-Ampel, au Cambodge.**